ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តភ្នំពេញ

លេខ.........៥០៤.........ក. ស. ភ.

ថ្ងៃពុធ ៥រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ២០២៦

សេចក្តីជូនដំណឹងលើកទី២
ស្តីពី
ការអញ្ជើញចូលរួមដេញថ្លៃជាសាធារណៈលើការផ្គត់ផ្គង់ កុំព្យូទ័រលើតុ (Desktop) ឧបករណ៍ទប់ភ្លើង (UPS) និងបញ្ជាទិញម៉ាស៊ីនមេ (Physical Server) ចំនួន ១សំរាប់ ប្រចាំឆ្នាំ២០២៦

កំពង់ផែស្វយ័តភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា កំពង់ផែស្វយ័តភ្នំពេញ នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈស្តីពីការផ្គត់ផ្គង់ កុំព្យូទ័រលើតុ (Desktop) ឧបករណ៍ទប់ភ្លើង (UPS) និងបញ្ជាទិញម៉ាស៊ីមេ (Physical Server) ចំនួន ១សំរាប់ ប្រចាំឆ្នាំ២០២៦។

កំពង់ផែស្វយ័តភ្នំពេញ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មកំពង់ផែស្វយ័តភ្នំពេញ ដែលមានអាសយដ្ឋានអគារលេខ ៦៤៩ តិរៈវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី៧...ខែឧសភាឆ្នាំ២០២៦ តទៅរៀងរាល់**ម៉ោងធ្វើការ** (ទូរស័ព្ទទាក់ទងលេខ ០១០ ៤៤៤ ៦៩៥/ ០១០ ៤៤៤ ៦៣៤)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង១៤:៣០.........ថ្ងៃទី២១...ខែឧសភា..ឆ្នាំ២០២៦។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ **វេលាម៉ោង** ១៤:៣០..........ថ្ងៃទី២១..ខែឧសភា..ឆ្នាំ២០២៦។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

ប្រធានគណៈកម្មាធិការលទ្ធកម្ម

ជួន សុខេម

ចម្លងជូន

- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ-កាលប្បវត្តិ